*[illegible]

ដែលហៅថា អានិសង្ស គឺ ការលោះកំហុសក្នុងសិក្ខាបទខ្លះៗ ឱ្យភិក្ខុបានធូរស្រួលផង ឱ្យភិក្ខុបានលាភដោយ ងាយផង ហៅថា អានិសង្ស មាន ៥ គឺ -:

**អនាមន្តចារោ** ១ **អសមាទានចារោ** ១ **គណភោជនំ** ១ **យាវទត្ថចីវរំ** ១ **យោ ច តត្ថ ចីវរុប្បាទោ សោ នេសំ ភវិស្សតិ** ១ រួមទៅមាន ៥ ។

ទី ១ **អនាមន្តចារោ** អានិសង្ស ទី ១នេះ អាធ្វើឱ្យភិក្ខុដែលបានក្រាលអនុមោទនា កឋិនរួចចាកអាបត្តិក្នុង ក្នុងចារិត្តសិក្ខាបទ ទី ៦ ក្នុងចេលកវគ្គនៃសុទ្ធកបាចិត្តយៈបាន ។ សេចក្តី នៅមានក្នុងអដ្ឋកថា មានសេចក្តី ពន្យល់ថា **អនាមន្តចារោតិ យាវ កឋិនំ ន ឧទ្ធរិយតិ តាវ អនាមន្តេត្វា ចរណំ កប្បិស្សតិ ចារិត្តសិក្ខាបទេន អនាបត្តិ ភវិស្សតីតិ អត្ថោ** កឋិននៅមិនទាន់ដោះដរាបណា ការដែលភិក្ខុមិនបានលាភិក្ខុផងគ្នាសិនហើយត្រាចទៅនឹងគួរ គឺថានិង មិនមានអាបត្តិ ក្នុងចារិត្ត សិក្ខាបទ ដរាបនោះ ។ ( មាននៅក្នុងគម្ពីរធម្មសម្ពហវិន័យ ) ។

ទី ២ **អសមាទានចារោ** អានិង្សទី ២នេះ អាចធ្វើឱ្យភិក្ខុបានក្រាល បានអនុមោទនា កឋិន រួចចាកអាបត្តិ ក្នុងទុតិយ កឋិនសិក្ខាបទ ទី ២ ក្នុងចីវរវគ្គ នៃអានិស្សគ្គិយបាចិត្តយៈបាន ។ ក្នុងអដ្ឋកថា លោកពន្យល់ថា ការដែលភិក្ខុមិនបានកាន់ យកនូវត្រៃចីវរ គឺស្បង ចិពរ សង្ឃាដី ហើយត្រាចទៅ ហៅថា អនាមន្តចារោ បានសេចក្តីថា ការនៅប្រាស់ចាកត្រៃចីវរ និងគួរ គឺថា និងមិនមានអាបត្តិឡើយ ( ដល់ភិក្ខុដែលបានក្រាលអនុមោទនាកឋិន ) ។

( មាននៅក្នុង សម្ពហវិន័យ ) ។

ទី ៣ **គណភោជនំ** អានិសង្ស ទី ៣ អាចធ្វើឱ្យភិក្ខុដែលបានក្រាល បានអនុមោទនា កឋិន រួចចាកអាបត្តិ ក្នុងគណភោជន សិក្ខាបទទី ២ ក្នុងភោជនវគ្គ នៃសុទ្ធិកបាចិត្តយៈបាន។ ក្នុងអដ្ឋថា ពន្យល់ថា **គណភោជនន្តិ គណភោជនម្បិ កប្បិស្សតិ** ។ គណភោជននិងគួរគឺថាមិនមានអាបត្តិឡើយ (ដល់ភិក្ខុដែលបានក្រាលអនុមោទនាកឋិន) ។ក្នុងគម្ពីរមហាវិភង្គ និង គម្ពីរផ្សេងៗ ដែលនិយាយពីគណភោជន មានសេចក្តីបន្យល់ថា ភិក្ខុទាំងឡាយ ៤ រូបឡើងទៅ ដែលទាយកគេនិមន្ត ដោយភោជន៥ យ៉ាងណា មួយ ទទួលនូវភោជនណា ភោជននោះហៅថា គណភោជន ។ គណៈក្នុងទីនេះសំដៅយកភិក្ខុ ៤ រូបឬច្រើនរូបឡើងទៅ។ សរុប សេចក្តីថា ក្នុងការដែលភិក្ខុទាំងនោះទទួលភោជន ៥ មានបាយជាដើម ភោជនណាមួយ ក្នុងទីជាមួយគ្នា ដោយការសូមខ្លួនឯងក្តី ដោយការនិមន្តរបស់ទាយកក្តី ហៅថា គណភោជន ។

ទី ៤ **យាវទត្ថចីវរំ** អានិសង្ស ទី ៤ អាចធ្វើឱ្យភិក្ខុដែលបានក្រាល បានអនុមោទនាកឋិន រួចាកអាបត្តិក្នុងបឋមកឋិនសិក្ខាបទ ទី ១ ក្នុងចីវរវគ្គនៃនិស្សគ្គិយ បាចិត្តយៈបាន ។ ក្នុងអដ្ឋកថា ថា យាវទត្ថចីវរន្តិ យាវតកេន ចីវរេន អត្ថោ តាវតកំ អនធិដ្ឋតំ អវិកប្បិតំ កប្បិស្សតីតិ អត្ថោ ។ សេចក្តីថាត្រូវការដោយចីវរ ចំនួនប៉ុន្មាន ចីវរចំនួនប៉ុណ្ណោះ ទោះបីមិនបានអធិដ្ឋាន មិនបានវិកប្បក៏គួរគឺថា មិនមានអាបត្តិឡើយ ។

ទី ៥ **យោ ច តត្ថ ចីវរុប្បាទោ សោ នេសំ ភវិស្សតិ**អានិសង្សទី ៥នេះ អាចធ្វើឱ្យភិក្ខុដែលបាមក្រាល បានអនុមោទនា កឋិន មានអំណាចទទួលចំណែកលាភ ដែលកើតឡើងក្នុងអាវាស ដែលខ្លួននៅ ចាំវស្សា ។ ក្នុងអដ្ឋកថា មានពន្យល់ថា **យោ ច តត្ថ ចីវរុប្បាទោតិ តត្ថ កឋិនត្ថតសីមាយំ មតកចីវរំ វា ហោតុ សង្ឃំ ឧទ្ទិស្ស ទិន្នំ វា សង្ឃិកេន តត្រុប្បាទេន អាភតំ វា យេន កេនចិ អាការេន យំ សង្ឃិកំ ចីវរំ ឧប្បជ្ជតិ តំ តេសំ ភវិស្សតីតិ អត្ថោ**។ ចីវររបស់ភិក្ខុ សាមណេរ ដែលធ្វើមរណកាលក្តី ចីវរដែលគេប្រគេនចំពោះសង្ឃក្តី ចីវរដែលគេនាំមកដោយទ្រព្យ

របស់សង្ឃក្តី ដែលគេធ្វើឡើងក្នុង ឧបចារ សីមា ដែលគេក្រាលកឋិននោះ នឹងត្រូវបានដល់ភិក្ខុដែលបានក្រាល បានអនុមោទនា កឋិន គ្រប់រូបនោះឯង ។

**ពាក្យថាមាតិកា** តាមអដ្ឋកថា លោកពន្យល់ថា មាតិការ គឺជាមាតា ឬជាអ្នកបង្កើត ព្រោះមាតិកា ទាំង ៨ នោះ ញុំាងកឋិនុព្ភារៈ គឺការដោះកឋិនឱ្យកើត ។

មាតិកា ៨ នោះ មានសេចក្តីពន្យល់តទៅនេះ គឺ

១ **បក្កមនន្តិកា មាតិកា** មានកិរិយាចៀសចេញទៅចាកកឋិននាវាស គឺអាវាសដែលក្រាល អនុមោទនា កឋិន ជាទីបំផុត ឬជាកំណត់ ។ សេចក្តីថា ភិក្ខុក្រាលកឋិន អនុមោទនាកឋិនរួចហើយ នាំយកចីវរដែលធ្វើស្រេចហើយចេញទៅចាកអាវាសដោយគិតថា អាត្មាអញនឹងមិនត្រឡប់វិញទេ ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះ ត្រង់ការ ចេញ ចាកអាវាសជាកំណត់។ កឋិនដោះពេលណា អានិសង្ស ៥ របស់ភិក្ខុនោះ ក៏ទៅក្នុងពេលនោះដែរ ។ មាតិកានេះចីវរបលិពោធដាច់មុន គឺថាដាច់តាំងពីនៅ ក្នុងអាវាស អាវាសបលិពោធ ដាច់ក្រោយ ។

២ **និដ្ឋានន្តិកា** មាតិកា មានកិរិយាសម្រេច នៃចីវរជាទីបំផុត ។ សេចក្តីថា ភិក្ខុបានក្រាល បានអនុមោទនា កឋិនហើយ នាំយកចីវរដែលមិនទាន់ធ្វើ ចេញទៅអំពីអាវាសដែលបានក្រាល បានអនុមោទនា កឋិន កាលដែលទៅ ដល់វត្តដទៃ ជិតខាងជាវត្តនៅខាងក្រៅឧបចារសីមាក៏មានគំនិតកើតឡើងថា((និងឱ្យគេធ្វើចីវរនៅទីនេះអញនិងមិនត្រឡប់វិញទេ))ភិក្ខុនោះក៏បានធ្វើចីវរ ក្នុងទីនោះទៅ ។គ្រាន់តែធ្វើចីវររួចស្រេចភ្លាម កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះក្នុងខណពេលដែលធ្វើចីវររួចស្រេចនុះឯង ។

(មាតិកានេះ អាវាស បលិពោធ ដាច់មុន ចីវរ បលិពោធ ដាច់ក្រោយ)

៣ **សន្និដ្ឋានន្តិកា**មាតិកាមានសន្និដ្ឋាន គឺសេចក្តីសំរេចចិត្តជាទីបំផុត ។សេចក្តីថា ភិក្ខុបានក្រាលបានអនុមោទនា កឋិនរួចហើយ នាំយកចីវរដែលមិនទាន់ធ្វើចេញទៅក្រៅពីអាវាសនេះទៅ កាលទៅដល់វត្តជាខាងក្រៅឧបចារសីមាក៏បានសំរេចចិត្តថា (អញនិងមិនរកគេឱ្យជួយធ្វើចីវរនេះទេទាំងវត្តដែលអាត្មាអញបានក្រាលបានអនុមោទនាកឋិនក៏អញមិនត្រឡប់ទៅវិញឡើយ) ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះក្នុងគ្រា ដែលសំរេចចិត្ត នោះឯង)

(មាតិកានេះ អាវាសបលិពោធ និង ចីវរបលិពោធ ដាច់ស្របគ្នា) ។

៤ **នាសនន្តិកា** មាតិកា មានកិរិយាវិនាសចីវរជាទីបំផុត ។

សេចក្តីថា ភិក្ខុបានក្រាល បានអនុមោទនាកឋិនរួចហើយ នាំយកចីវរដែលមិនទាន់ធ្វើចេញពីអាវាសទៅ កាលទៅដល់វត្តជាខាងក្រៅឧបចារសីមា ក៏គិតថា អញនិងឱ្យគេជួយធ្វើចីវរក្នុងទីនេះ អញមិនត្រឡប់ទៅកាន់វត្តដើមវិញទេ លុះកំពុងតែធ្វើចីវរក៏ត្រូវវិនាសដោយហេតុណាមួយមានចោរ ឬ ភ្លើងឆេះជាដើម ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះក្នុងគ្រាវិនាសនោះ(មាតិកានេះអាវាសបលិពោធ ដាច់មុន ចីវរបលិពោធ ដាច់ក្រោយ) ។

៥ **សវនន្តិកា** មាតិកា មានកិរិយា ឮ ដំណឹងជាទីបំផុត ។ សេចក្តីថា ភិក្ខុបានក្រាល បានអនុមោទនាកឋិនរួចហើយ នាំយកចីវរដែលមិនទាន់ធ្វើចេញពីអាវាសទៅ ដោយគិតថា អាត្មាអញនិងត្រឡប់វិញ ;កាលទៅដល់វត្តជាខាងក្រៅឧបចារសីមាក៏ឱ្យគេជួយធ្វើចីវរ លុះធ្វើហើយក៏បានឮដំណឹងថា (សង្ឃក្នុងវត្តសូត្រដោះកឋិនហើយ) ។

កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះក្នុងគ្រាដែលបានឮ ដំណឹងនុះឯង ។

៦ **អាសាវច្ឆេទិកា** មាតិកាប្រកបដោយកិរិយាដាច់បំណង ឬ ការអស់សេចក្តីសង្ឃឹម ។សេចក្តីថាភិក្ខុបានក្រាលបាន អនុមោទនា កឋិនរួចហើយ ចេញពីអាវាសទៅដោយមានបំណងស្វែងរកចីវរក្នុងទីដទៃទៀត លុះទៅដល់ខាងក្រៅឧបចារសីមា ក៏គិតថា( អញនឹងស្វែងរកចីវរតែក្នុងទីខាងក្រៅឧបចារសីមានេះអញនឹងមិនត្រឡប់ទៅវត្តវិញទេ) ភិក្ខុនោះក៏ស្វែងរកចីវរក្នុងទីនោះ លុះដល់ស្វែងរកចីវរ ក៏ដាច់ឬអស់ទៅ ។កឋិនរបស់ភិក្ខុនោះក៏ដោះក្នុងគ្រាដាច់បំណង ឬ អស់សេចក្តីសង្ឃឹម ក្នុងការស្វែងរកចីវរនុះឯង ។

( ក្នុងមាតិកានេះ អាវាសបលិពោធ ដាច់មុន ចីវរបលិពោធ ដាច់ក្រោយ ) ។

៧ **សីមាតិក្កន្តិកា** មាតិកា មានកិរិយាកន្លងនូវ សីមា គឺខេត្តនៃកឋិនជាទីបមផុត ។ សេចក្តីថា ភិក្ខុបានក្រាល បានអនុមោទនាកឋិនរួចហើយ នាំយកចីវរដែលមិនទាន់ធ្វើចេញពីអាវាសទៅគិតថា( អញនឹងត្រឡប់វិញ) លុះទៅដល់ខាងក្រៅឧបចារសីមា ក៏ឱ្យគេជួយធ្វើចីវរនោះ ។ កាលដែលធ្វើចីវររួចហើយ ក៏នៅតែគិតថា អញនឹងត្រឡប់វិញ )ប៉ុន្តែមិនទាន់ត្រឡប់ ក៏ចេះតែនៅខាងក្រៅឧបចារសីមានោះ គ្រាតែដល់កំណត់កាលដែល កឋិនដោះគឺកន្លងហួសថ្ងៃ ១៥កើតខែផល្គុណ ទៅកឋិនរបស់ភិក្ខុនោះ ក៏ដោះក្នុងគ្រា ដែលគន្លងហួសសីមាគឺគន្លងហួសខែត្រ កឋិន ។

( ក្នុងមាតិកានេះ ចីវរបលិពោធ ដាច់មុន អាវាស បលិពោធដាច់ក្រោយ ) ។

៨ **សហុព្ភារា** មាតិកា មានការដោះកឋិន រួមជាមួយ និងភិក្ខុទាំងឡាយ ។ សេចក្តីថា ភិក្ខុបានក្រាលបាន អនុមោទនាកឋិនរួចហើយ នាំយកចីវរដែលមិនទានធ្វើចេញពីអាវាសទៅគិតថា( អញនឹងត្រឡប់វិញ) កាលទៅដល់ខាងក្រៅឧបចារសីមា ក៏បានឱ្យគេជួយធ្វើចីវរនោះ លុះធ្វើចីវររួចហើយ គិតថា (នឹងត្រឡប់វិញ) ហើយបានត្រឡប់ មកទានពេលដោះកឋិន ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះជាមួយនិងភិក្ខុទាំងឡាយ ។

( ក្នុងមាតិកានេះ បលិពោធទាំងពីរដាច់ស្មើគ្នា មិនមុនមិនក្រោយ គឺដាច់ក្នុងពេលដែលចប់កម្មវាចា ) ។

**ពាក្យថា បលិពោធ ( កង្វល់ )**

ក្នុងគម្ពីរមហាវគ្គ មានព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ បលិពោធ ( កង្វល ) របស់កឋិន មានពីរយ៉ាង គឺ

១ **អាវាសបលិពោធ** នៅក្នុអាវាសដែលបាន**ក្រាលអនុមោទនាកឋិននោះ** មានសេចក្តី អាល័យចំពោះ អាវាសដែលខ្លួន នៅនោះ កាលចេញពីអាវាសនោះទៅ នៅមានបំណងថាអាត្មាអញនឹង ត្រឡប់មកវិញ យ៉ាងនេះ ហៅថា អាវាសបលិពោធ គឺ ភិក្ខុអ្នកក្រាល អ្នកអនុមោទនា កឋិន នៅមានកង្វលក្នុងអាវាស ។

២ **ចីវរបលិពោធ** (កង្វល់ចំពោះចីវរ)សេចក្តីថា ភិក្ខុក្នុងសាសនានេះ មិនទានធ្វើចីវរ ឬធ្វើមិនទាន់រួចស្រេចឬក៏សេចក្តីប្រាថ្នាចំពោះចីវរមិនទាន់ដាច់នៅឡើយ,យ៉ាងនេះ ហៅថា ចីវរបលិពោធគឺភិក្ខុអ្នកក្រាលអ្នកអនុមោទនា កឋិននៅមានកង្វល់ចំពោះចីវរ (ដែលត្រូវស្វែងរក ឬដែលត្រូវធ្វើ ឱ្យមានគ្រប់គ្រាន់ល្មមប្រើប្រាស់បាន ) ។

# អនន្តរាការ ២៤ គឺ

ព្រះពុទ្ធដីកាក្នុងគម្ពីរ មហាវគ្គថា កឋិនដែលភិក្ខុក្រាលមិនឡើង ដោយអាការ ២៤ យ៉ាងគឺ

ទី ១ **ឧល្លិខិតមត្តេន** ភិក្ខុក្រាលកឋិន ដោយសំពត់ដែលគ្រាន់តែវាស់គូសស្ទង់មើលបណ្តោយទទឹងប៉ុណ្ណោះ ។

ទី ២ **ធោវនមត្តេន** ភិក្ខុក្រាលកឋិន ដោយសំពត់ដែលគ្រាន់តែបោកគក់លាង ។

ទី ៣ **ចីវរវិចារណមត្តេន** ភិក្ខុក្រាលកឋិន ដោយសំពត់ដែលគ្រាន់តែចាត់ចែងលៃលកទុកដាក់យ៉ាង នោះថា នេះជាចីវរបញ្ចខណ្ឌ នេះជាចីវរសត្តខណ្ឌ នេះជាចីវរនវខណ្ឌ នេះជាចីវរ ឯកាទសខណ្ឌ ។

ទី ៤ **ឆេទនមត្តេន** ភិក្ខុក្រាលកឋិនដោយសំពត់ដែលគ្រាន់តែកាត់តាមបែបដែលបានចាត់ចែងលៃលកទុក ។

ទី ៥ **ពន្ធនមត្តេន** ភិក្ខុក្រាលកឋិន ដោយសំពត់ដែលដែលគ្រាន់តែដានផ្តុំភ្ជាប់គ្នា ។

ទី ៦ **ឱវដ្ដិយករណមត្តេន** ភិក្ខុក្រាលកឋិន ដោយសំពត់ដែលគ្រាន់តែដេរថ្នេរវែង ១ ឬ រង្វិល ១ ។

ទី ៧ **កណ្ឌុសករណមត្តេន** ភិក្ខុក្រាលកឋិន ដោយសំពត់ ដែលគ្រាន់តែភ្ជាប់ក្ដុំ ។

ទី ៨ **ទឡ្ហីកម្មករណមត្តេន** ភិក្ខុក្រាលកឋិន ដោយសំពត់ ដែលគ្រាន់តែថែមសំពត់ ដើម្បីធ្វើឱ្យមាំ ។

ទី៩ **អនុវាតករណមត្តេន** ភិក្ខុក្រាលកឋិន ដោយគ្រាន់តែលើកឡើង នូវអនុវាតខាងបណ្តោយ ឬ អនុវាតខាងខ្នង ។

ទី១០ **បរិភណ្ឌករណមត្តេន** ភិក្ខុក្រាលកឋិន ដោយសំពត់ដែលគ្រាន់តែលើកឡើង នូវអនុវាត ខាងទទឹង ឬ អនុវាតខាងពោះ ។

ទី១១ **ឱវដ្ដេយ្យករណមត្តេន** ភិក្ខុក្រាលកឋិន ដោយសំពត់ដែលគ្រាន់តែលើកបញ្ចូលផ្ទាំងសំពត់ថ្មី ពុំនោះគ្រាន់តែលើកផ្ទាំង សំពត់អំពីកឋិនចីវរ ។ ទៅដាក់បញ្ចូលក្នុងកឋិនចីវរ ឯទៀត ។

ទី១២ **កម្ពលមទ្ទនមត្តេន** ភិក្ខុក្រាលកឋិនដោយសំពត់ដែលគ្រាន់ តែដាក់ក្នុងទឹកជ្រលក់ ១ ដង មានពណ៌ដូចភ្លុកដំរី ឬ ស្លឹកឈើទុំលឿង ។

ទី១៣ **និមិត្តកតេន** ភិក្ខុក្រាលកឋិន ដោយសំពត់ដែលបានមកដោយសារធ្វើនិមិត្តកម្ម គឺនិយាយបញ្ឆិតបញ្ឆៀងថា អាត្មានឹងក្រាលកឋិនដោយសំពត់បែបនេះ ឬ និយាយថា សំពត់សាដកនេះល្អ អាត្មាអាចនឹងក្រាលកឋិននេះ ដោយសំពត់នេះបាន ។

ទី១៤ **បរិកថាកតេន** ភិក្ខុក្រាលកឋិនដោយ សំពត់ដែលកើតឡើង ដោយសារការនិយាយបញ្ចុះបញ្ចូល ទាយកថា ការប្រគេនសំពត់កឋិន ជាការល្អ ជាការគួរ ព្រោះទាយកអ្នកប្រគេនសំពត់កឋិន រមែងបាន ទទួលនូវ ផលបុណ្យ ដ៏ល្អប្រសើរ ។ អដ្ឋកថាបានពន្យល់ថា ធម្មតាសំពត់កឋិន ទាល់តែឧក្រិដ្ឋណាស់ ទើបគួរភិក្ខុនិយាយបញ្ចុះបញ្ចូល សូម្បីតែមាតាបរស់ខ្លួន ក៏មិនគួរដែរ លុះតែសំពត់នោះប្រាកដដូចជាធ្លាក់ចុះពីលើអាកាសទើបគួរ ។

ទី ១៥ **កុក្កុកតេន** ភិក្ខុក្រាលកឋិនដោយសំពត់ខ្ចីគេ ឬដោយសំពត់ដែលមិនមានទាយកនាំមកប្រគេន គឺសំពត់ស្វែងរកដោយខ្លួនឯង ។

ទី ១៦ **សន្និធិកតេន** ភិក្ខុក្រាលកឋិនដោយសំពត់ធ្វើ ឱ្យទៅជាសន្និធិ គឺសំពត់នៅដៃសង្ឃ ឬ នៅដៃនៃភិក្ខុ អ្នកក្រាលឱ្យរំលងថ្ងៃ គឺមិនក្រាលឱ្យស្រេចក្នុងថ្ងៃនោះ ។

សន្និធិក្នុងទីនេះ សំដៅយកអាការនេះមានពីរយ៉ាង ករណសន្និធិ ១ និចយសន្និធិ ១ ។ **ការដែលភិក្ខុអ្នក**ក្រាល តម្កល់សំពត់កឋិនទុកមិនធ្វើឱ្យហើយក្នុងថ្ងៃនោះ ហៅថាករណសន្និធិ ។ សង្ឃបានសំពត់កឋិនមកថ្ងៃនេះ **ដល់ថ្ងៃ ស្អែកទើប**ប្រគល់ឱ្យទៅភិក្ខុអ្នកក្រាល ហៅថា និចយសន្និធិ ។

ទី ១៧ **និស្សគ្គិយេន** ភិក្ខុក្រាលកឋិន ដោយចីវរជានិស្សគ្គិយ គឺចីវរកំពង់តែធ្វើទទួលអរុណរះឡើង ឬ ចីវរ កន្លងរាត្រី ។

ទី ១៨ **អកប្បកតេន** ភិក្ខុក្រាលកឋិន ដោយចីវរដែលមិនបានធ្វើពិន្ទុកប្បៈ ។

ទី ១៩ **អញ្ញត្រ សង្ឃាដិយា** ភិក្ខុក្រាលកឋិន ដោយសំពត់ក្រៅពីសង្ឃាដិ មានសំពត់កម្រាលជាដើម ។

ទី ២០ **អញ្ញត្រ ឧត្តរាសង្គេន** ឬ ភិក្ខុក្រាលកឋិនដោយ សំពត់ក្រៅអំពីឧត្តរាសង្គៈមានសំពត់ម្រាល ជាដើម ។

ទី ២១ **អញ្ញត្រ អន្តរវាសកេន** ឬ ក៏ក្រាលកឋិនដោយសំពត់ក្រៅពីអន្តរវាសកៈ មានសំពត់កម្រាល ជាដើម ។

ទី ២២ **អញ្ញត្រ បញ្ចកេន វា អតិរេក បញ្ចកេន វា តទហេវ សញ្ឆិន្នេន សមណ្ឌលីកតេន** ភិក្ខុក្រាលកឋិនដោយចីវរក្រៅពីចីវរដែលបានកាត់ជាបញ្ចខណ្ឌ ឬ លើសពីបញ្ចខណ្ឌឡើងទៅ គឺសត្តខណ្ឌ នវខណ្ឌ និង ឯកាទសខណ្ឌ ព្រមទាំងធ្វើឱ្យប្រកបដោយមណ្ឌលគឺ មហាមណ្ឌល និង អឌ្ឍមណ្ឌល ក្នុងថ្ងៃនោះឯង បានសេចក្តីថា ក្រាលកឋិន ដោយចីវរមិនបានប្រកបដោយលក្ខណៈត្រឹមត្រូវ មានមិនបានកាត់ បញ្ចខណ្ឌ មាន កន្ទៀងធំ ៥ មានកន្ទៀងតូច ៥ ) ជាដើម ។

ទី ២៣ **អញ្ញត្រ បុគ្គលស្ស អត្ថារា** វៀរលែងការក្រាល របស់បុគ្គល គឺមិនឱ្យបុគ្គលត្រឡប់ជាឱ្យ សង្ឃក្រាល វិញ ។

ទី ២៤ **ន សម្មា ចេវ អត្ថតំ ហោតិ តញ្ចេ និស្សីមដ្ឋោ អនុមោទតិ** បើបុគ្គលនៅក្រៅសីមា អនុមោទនា នូវកឋិនណោកឋិននោះ ឈ្មោះថាក្រាលមិនត្រឹមត្រូវឡើយ ។

កឋិនដែលភិក្ខុក្រាលមិនឡើងជាកឋិន ដោយអាការ ២៤ នេះឯង ។

## អត្ថតាការ

អាការដែលភិក្ខុក្រាលបានឡើងពេញលក្ខណៈជាកឋិន ហៅថា អត្ថតាការ ។
តាមព្រះពុទ្ធដីកា ក្នុងគម្ពីរមហាវគ្គថា កឋិនដែលភិក្ខុក្រាលឡើង ដោយអាការ ១៧ គឺ

ទី ១ **អហតេន** ភិក្ខុក្រាលកឋិន ដោយចីវរធ្វើដោយសំពត់ថ្មី សុទ្ធគឺសំពត់ដែលគេមិនទាន់ប្រើ ។

ទី ២ **អហតកប្បេន** ភិក្ខុក្រាលកឋិន ដោយចីវរធ្វើដោយសំពត់ដែលបោកគក់ ១ ដង ឬ ២ ដង ប្រាកដដូចជាសំពត់ថ្មី សុទ្ធ ។

ទី ៣ **បិលោតិកាយ** ភិក្ខុក្រាលកឋិន ដោយចីវរធ្វើដោយសំពត់សាដកចាស់ ។

ទី ៤ **បំសុកូលេន** ភិក្ខុក្រាលកឋិនដោយចីវរធ្វើដោយសំពត់បំសុកូល ដែលកើតឡើងក្នុងបំសុកូលខេត្រ ២៣ ដែលគេយកមកវេរប្រគេន ។

ទី ៥ **អាបណិកេន** ភិក្ខុក្រាលកឋិនដោយចីវរ ធ្វើដោយសំពត់ដែលធ្លាក់ចុះក្បែទីផ្សារ ដែលទាយករើសយកមកវេរ ប្រគេន ។

ទី ៦ **អនិមិត្តកតេន** ភិក្ខុក្រាលកឋិន ដោយចីវរដែលកើតឡើងដោយធម៌ គឺមិនបានធ្វើនិមិត្តកម្ម បញ្ចិតបញ្ចៀងឱ្យទាយកគេវេរប្រគេនឡើយ ។

ទី ៧ **អបរិកម្មកតេន** ភិក្ខុក្រាលកឋិន ដោយចីវរដែលកើតឡើង ដោយធម៌គឺមិនបានទៅនិយាយបញ្ចុះបញ្ចូលឱ្យគេវេរប្រគេនឡើយ ។

ទី ៨ **អកុក្កុកតេន** ភិក្ខុក្រាលកឋិន ដោយចីវរដែលទាយកគេវេរប្រគេន មិនមែនចីវរដែលខ្ចីគេឡើយ ។

ទី ៩ **អសន្និធិកតេន** ភិក្ខុក្រាលកឋិន ដោយចីវរដែលមិនបានធ្វើឱ្យជាសន្និធិ ។

ទី ១០ **អនិស្សគ្គិយេន** ភិក្ខុក្រាលកឋិន ដោយចីវរដែលមិនមែនជានិស្សគ្គិយៈ ។

ទី ១១ **កប្បកតេន** ភិក្ខុក្រាលកឋិន ដោយចីវរដែលគេបានធ្វើពិន្ទុកប្បៈរួចហើយ ។

ទី ១២ **សង្ឃាដិយា** ភិក្ខុក្រាលកឋិន ដោយសង្ឃាដី ។

ទី ១៣ **ឧត្តរាសង្គេន** ភិក្ខុក្រាលកឋិន ដោយឧត្តរាសង្គ ។

ទី ១៤ **អន្តរវាសកេន** ឬ ភិក្ខុក្រាលកឋិន ដោយអន្តរវាសកៈ ។

( អាការទី ១២ ទី ១៣ និងទី ១៤ នេះមិនមែនត្រូវយកទាំង ៣ មកក្រាលកឋិនទេ ភិក្ខុអ្នកក្រាលកឋិនត្រូវជ្រើស រើសយកតែ ១ មកក្រាល ) ។

ទី ១៥ **បញ្ចកេន វា អតិរេកបញ្ចកេន វា តទហេវ សញ្ឆិន្នេន សមណ្ឌលីកតេន** ភិក្ខុក្រាលកឋិន ដោយចីវរដែលបានកាត់ដាច់ជាបញ្ចខណ្ឌ ឬ ជាអតិរេកបញ្ចខណ្ឌ គឺសត្តខណ្ឌ នវ ខណ្ឌ និង ឯកាទសខណ្ឌ ព្រមទាំងធ្វើឱ្យប្រកប ដោយមណ្ឌល គឺមហាមណ្ឌល និងអឌ្ឍមណ្ឌលឱ្យហើយស្រេចក្នុងថ្ងៃនោះ ។

ទី ១៦ **បុគ្គលស្ស អត្ថារា** មិនវៀរលែងចាកការក្រាលរបស់បុគ្គល គឺភិក្ខុមួយរូបជាចចាអ្នកក្រាល មិនមែនសង្ឃ ឬ គណៈជាអ្នកក្រាលឡើយ ។

ទី ១៧ **សម្មា ចេច អត្ថតំ ហោតិ តញ្ចេ សីមាដ្ឋោ អនុមោទតិ** បើភិក្ខុនៅក្នុងសីមា អនុមោទនាកឋិនណា កឋិននោះឈ្មោះថាក្រាលត្រឹមត្រូវ ។

កឋិនដែលភិក្ខុក្រាលឡើង ដោយអាការៈ ទាំង ១៧ នោះឯង ។

**ការក្រាលកឋិនរបស់បុគ្គល ៣ ពួក មិនឡើងជាកឋិនឡើយ**

- បុគ្គលឋិននៅក្រៅឧបចារសីមា ក្រាល-អនុមោទនាកឋិន ១
- បុគ្គលក្រាលអនុមោទនា កឋិន មិនបញ្ចេញវាចា ១
- បុគ្គលកាលបញ្ចេញ វាចា មិនឱ្យអ្នកដទៃ ដឹងសេចក្តី ច្បាស់ ១ ។

**ការក្រាលកឋិនរបស់បុគ្គលក្រៅ ពីនេះទើបឡើងជាកឋិន គឺ**

- បុគ្គលឋិននៅក្នុងឧបចារសីមា ក្រាលអនុមោទនាកឋិន ១
- បុគ្គលកាលក្រាល អនុមោទនាកឋិនបានបញ្ចេញវាចា ១
- បុគ្គលកាលបញ្ចេញ វាចា បានឱ្យអ្នកដទៃដឹងសេចក្តីច្បាស់ ១ ។

ការក្រាលកឋិន ៣យ៉ាងទៀត មិនឡើងជាកឋិនឡើយ

- ១ វត្ថុវិបន្ន វត្ថុ បានដល់សំពត់កឋិនជាអកប្បិយៈ គឺ ចីវរមិនត្រឹមត្រូវ ។

២ កាលវិបន្ន កាលខុស បានដល់ការដែលទាយកប្រគេន សំពត់ក្នុងថ្ងៃនេះ សង្ឃប្រគល់ដល់ភិក្ខុអ្នកក្រាល ក្នុងថ្ងៃស្អែក ។

៣ ករណវិបន្ន ធ្វើខុស បានដល់ការមិនធ្វើសំពត់ នៅថ្មីសុទ្ធ ឱ្យទៅជាចីវរត្រឹមត្រូវ ឱ្យទាន់ក្នុងថ្ងៃនោះ ។